**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងបរិស្ថាន**

Ministry of Environment

លេខ: ០១៦២ ស.-ក ប.ស្ក

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ មករា ឆ្នាំ២០១៣

# ប្រកាស
# ស្តីពីការដាក់ឲ្យអនុវត្តប្រកាសរួមស្តីពី ការផ្តល់សេវាសាធារណៈ និងការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងបរិស្ថាន

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦.២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៩០៨.១០៥៧ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញាឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០១ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ ស្តីពីតម្លើងអធិការដ្ឋានរបស់ក្រសួងបរិស្ថាន ទៅជាអគ្គាធិការដ្ឋាន
- យោងអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិរបស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ
- ប្រកាសរួមលេខ: ៩៩៩ សហវ.ប្រក និងលេខ: ១០០០ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២
- យោងការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១** : ត្រូវបានអនុញ្ញាតឲ្យអង្គភាពនៅរដ្ឋបាលកណ្តាលរួមមាន អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នាយកដ្ឋានអង្កេតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃអគ្គនាយកបច្ចេកទេស លេខាធិការដ្ឋានជីវសុវត្ថិភាព និងគ្រប់មន្ទីរបរិស្ថានរាជធានី-ខេត្ត អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណាប្រយោជន៍ថវិកាជាតិ។

- ត្រូវបានអនុញ្ញាតឲ្យអង្គភាពប្រមូលចំណូលដកទុកសម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល ។

**ប្រការ២** : ការរៀបចំ និងការប្រព្រឹត្តទៅ នៃការប្រមូលចំណូល ការដកទុក ប្រាក់រង្វាន់លើកទឹកចិត្ត ក្រសួងនឹងមានសេចក្តីណែនាំអនុវត្តជាក់ស្តែងដោយឡែក។

**ប្រការ៣** : គ្រប់អង្គភាពប្រមូលចំណូល ដូចប្រការ១ ត្រូវមានសេចក្តីកំណត់ជាក់ស្តែងអំពីការប្រមូលចំណូល ការដកទុកការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រីដោយធានាឲ្យបានការឯកភាពផ្ទៃក្នុងអង្គភាពនីមួយៗ ។

**ប្រការ៤** : ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការ គ្រប់មន្ទីរបរិស្ថានរាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

ម៉ុក_ម៉ារ៉េត

បណ្ឌិត.ពិភិម្យ

**ចំលងជូន** :

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់អង្គភាពចំណុះក្រសួង

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ